IHSS
IN-HOME SUPPORTIVE SERVICES

CDSS

# ការសម្រេចចិត្តថាពេលណាត្រូវបញ្ឈប់អ្នកផ្តល់សេវាពីការងារ

ក្នុងនាមជានិយោជក អ្នកមានសិទ្ធិបញ្ឈប់អ្នកផ្តល់សេវារបស់អ្នកពីការងារ សម្រាប់ហេតុផលណាមួយ ប៉ុន្តែអ្នកគួរតែគិតអំពីការសម្រេចចិត្តនេះដោយប្រុងប្រយ័ត្ន មុនពេលអ្នកចាត់វិធានការ។

## តើបញ្ហាទាំងនេះអាចនឹងដោះស្រាយបានឬទេ?

វាអាចពិបាកក្នុងការប្រាប់នរណាម្នាក់ថាអ្នកលែងត្រូវការសេវាកម្មរបស់ពួកគេទៀតហើយ។ ព្យាយាមរកដំណោះស្រាយលើបញ្ហាតូចតាចណាមួយជាមួយអ្នកផ្តល់សេវារបស់អ្នក មុនពេលអ្នកសម្រេចចិត្តបញ្ឈប់គាត់ពីការងារ។

## ពិភាក្សាជាមួយអ្នកផ្តល់សេវារបស់អ្នកអំពីកង្វល់របស់អ្នក។

- ព្យាយាមប្រាប់អ្នកផ្តល់សេវារបស់អ្នកភ្លាមៗ នៅពេលដែលអ្នកឃើញមានបញ្ហា។ យកល្អកុំបណ្តោយឱ្យបញ្ហានោះកើតឡើង។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើបញ្ហានោះកើតឡើង សូមធ្វើបញ្ជីនៃអ្វីដែលអ្នកមិនសប្បាយចិត្ត ហើយសម្រេចចិត្តថាអ្វីដែលត្រូវផ្លាស់ប្តូរ ដើម្បីឱ្យអ្នកបន្តជួលអ្នកផ្តល់សេវារបស់អ្នក។ ពិភាក្សាដោយបើកចំហជាមួយអ្នកផ្តល់សេវារបស់អ្នក និងឈានដល់កិច្ចព្រមព្រៀងអំពីការធ្វើឱ្យបានប្រសើរនូវកិច្ចការណាមួយដែលអ្នកត្រូវការ ដើម្បីមើលឃើញនៅក្នុងការអនុវត្តការងាររបស់គាត់។ ប្រាប់គាត់ថានៅពេលណាដែលការធ្វើឱ្យប្រសើរឡើងនឹងត្រូវបានធ្វើ។
- ត្រូវចងចាំថា ទំនាក់ទំនងគឺជាផ្លូវរវាងទ្វេរភាគី។ អនុញ្ញាតឱ្យអ្នកផ្តល់សេវារបស់អ្នកសួរសំណួរ និងបើកចំហចំពោះគំនិត និងកង្វល់ទាំងឡាយដែលគាត់អាចមាន។
- ប្រសិនបើ អ្នកមានអារម្មណ៍មិនស្រួលក្នុងការនិយាយរឿងនេះតែម្នាក់ឯង សូមសួរមិត្តភក្តិ ឬសមាជិកគ្រួសារម្នាក់ ឱ្យនៅទីនោះដើម្បីជួយគាំទ្រអ្នក។

## ប្រសិនបើអ្នកផ្តល់សេវារបស់អ្នក មិនមានបំណងធ្វើកិច្ចការឱ្យបានប្រសើរឡើង៖

ប្រសិនបើ អ្នកផ្តល់សេវារបស់អ្នកមិនធ្វើកិច្ចការរបស់គាត់ឱ្យបានប្រសើរឡើងទេ វាអាចនឹងត្រូវដល់ពេលដែលត្រូវបញ្ចប់ការងាររបស់គាត់។ ប្រសិនបើអាចធ្វើបាន វាជាការល្អបំផុតក្នុងការជូនដំណឹងដល់អ្នកផ្តល់សេវារបស់អ្នករយៈពេលពីរសប្តាហ៍។ នេះនឹងផ្តល់ឱ្យគាត់នូវពេលវេលាដើម្បីស្វែងរកការងារថ្មី ហើយអ្នកមានពេលដើម្បីទទួលបានអ្នកផ្តល់សេវាថ្មីផងដែរ។

## បញ្ឈប់អ្នកផ្តល់សេវាដែលមិនមានសុវត្ថិភាពភ្លាមៗ!

ប្រសិនបើអ្នកផ្តល់សេវារបស់អ្នកកំពុងប្រព្រឹត្តចំពោះអ្នកក្នុងលក្ខណៈបំពាន ឬគំរាមកំហែង អ្នកគួរតែបញ្ឈប់គាត់ពីការងារជាបន្ទាន់ ហើយទាក់ទងទៅភ្នាក់ងារមានសមត្ថកិច្ច និង/ឬ សេវាការពារមនុស្សពេញវ័យ។ សុវត្ថិភាពផ្ទាល់ខ្លួនរបស់អ្នកគឺជាការសំខាន់បំផុត។ ប្រសិនបើអ្នកត្រូវការជំនួយក្នុងការធ្វើដូចនេះ សូមទូរស័ព្ទទៅការិយាល័យខោនធីផ្នែក IHSS, មិត្តភក្តិ ឬសមាជិកគ្រួសាររបស់អ្នក ដើម្បីឱ្យគេជួយអ្នក។

**ហេតុផលមួយចំនួនសំរាប់ការបណ្តេញអ្នកផ្តល់សេវា អាចជា៖**

- មិនបំពេញតាមតម្រូវការថែទាំរបស់អ្នក
- លួចលុយ ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នក
- មកយឺតពេលជាញឹកញាប់ ឬមិនមកធ្វើការទាល់តែសោះ
- ប្រើប្រាស់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នកដោយគ្មានការអនុញ្ញាត

IHSS IN-HOME SUPPORTIVE SERVICES

CDSS

ប្រសិនបើអ្នកត្រូវបញ្ឈប់អ្នកផ្តល់សេវារបស់អ្នកពីការងារដោយមិនមានការជូនដំណឹង អ្នកមានជម្រើសជាច្រើនដើម្បីស្វែងរកមនុស្សថ្មីយ៉ាងឆាប់រហ័ស៖

- ទាក់ទងទៅអាជ្ញាធរសាធារណៈរបស់អ្នក សំរាប់បញ្ជីរាយឈ្មោះអ្នកផ្តល់សេវាដែលអាចរកបាន។
- សុំជំនួយពីសមាជិកគ្រួសារ ឬមិត្តភ័ក្តិក្នុងរយៈពេលខ្លី (សូមចាំថា អ្នកផ្តល់សេវាទាំងអស់ត្រូវតែដាក់ផ្តិតម្រាមដៃ និងឆ្លងកាត់ការត្រួតពិនិត្យសាវតាឧក្រិដ្ឋកម្មដែលត្រូវបង់ដោយកម្មវិធី IHSS) ។

សូមទាក់ទងទៅការិយាល័យខោនធីផ្នែក IHSS របស់អ្នកជានិច្ច ប្រសិនបើអ្នកផ្លាស់ប្តូរអ្នកផ្តល់សេវា។

**សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យខោនធីផ្នែក IHSS ក្នុងតំបន់របស់អ្នក។**